ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ: ៤៥៧ មស.ក្រប

### សូមគោរពជូន
### សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
### រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន

**កម្មវត្ថុ** ៖ ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៧។

**យោង** ៖ - ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើរបាយការណ៍ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ
- របាយការណ៍ស្តីពីផែនការក្របខណ្ឌឆ្នាំ២០១៧ របស់ក្រសួង ស្ថាប័ន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានយល់ព្រមផ្តល់គោលការណ៍ជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលចំនួន ៦.៤០២ កន្លែង មន្ត្រីជាប់កិច្ចសន្យាចំនួន ១៨.៣៦៣ នាក់ គ្រូបង្រៀនចំណេះដឹងទូទៅចំនួន ៥.៩៨៧ នាក់ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន ២.៤៧២ នាក់ និងគ្រូបង្រៀនថ្នាក់ពីរវេននិងថ្នាក់គួបគ្រប់កម្រិតចំនួន ១៦.៥១៨ នាក់ ដើម្បីផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត សម្រាប់ឆ្នាំ២០១៧ ដូចមានបែងចែកតាមចំនួនដូចខាងក្រោម៖

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៧ | | | | | |
|---|---|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនទូទៅ ជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅ | គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | គ្រូបង្រៀនពីរវេននិងថ្នាក់គួបគ្រប់កម្រិត |
| ១ | ព្រះបរមរាជវាំង | ០៦ | ២៥០ | | | | |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២៣ | ១៣០ | | | | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១១ | ៥២ | | | | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | ១៤៣ | | | | |



ផ្លូវលេខអង្គតាមិញ ភូមិគោកចំបក់ សង្កាត់រហាមហាត់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៤០១/+៨៥៥-២៣-៨៦៦៤០៥ | គេហទំព័រ : http://www.mcs.gov.kh

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៧ | | | | | |
|---|---|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅ | គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | គ្រូបង្រៀនពីរវេននិងថ្នាក់គួបគ្រប់កម្រិត |
| ៥ | មហាផ្ទៃ | ៥៥០ | ១៣៨៤ | | | | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច[1] | ០០ | ២៣១ | | | | |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១៦ | ១០០ | | | | |
| ៨ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១៣៤ | ៤៧៥ | | | | |
| ៩ | ព័ត៌មាន | ៦០ | ៧១៥ | | | | |
| ១០ | សុខាភិបាល | ៧១០ | ៣៤០៧ | | | | |
| ១១ | រ៉ែនិងថាមពល | ៣៧ | ២០០ | | | | |
| ១២ | ផែនការ | ២១ | ២៤១ | | | | |
| ១៣ | ពាណិជ្ជកម្ម | ៥៣ | ១៩៦ | | | | |
| ១៤ | អប់រំ យុវជន និងកីឡា | ៣៥០០ | ៤៦៨ | | ៥៩៨៧ | ២៤៧២ | ១៦៥១៨ |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ១៨៤ | ១០២៤ | | | | |
| ១៦ | វប្បធម៌និងវិចិត្រសិល្បៈ | ៩៣ | ៨០៧ | | | | |
| ១៧ | បរិស្ថាន | ៤៦ | ៣៥៣ | | | | |
| ១៨ | អភិវឌ្ឍន៍ជនបទ | ៥១ | ៨៧ | | | | |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤១ | ៧៤៧ | | | | |
| ២០ | ប្រៃសណីយ៍និងទូរគមនាគមន៍ | ៦០ | ១២៦ | | | | |
| ២១ | ធម្មការនិងសាសនា | ២៣ | ៧២៣ | | | | |
| ២១.១ | អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ | ៥០ | | ១៤៦២ | | | |
| ២២ | កិច្ចការនារី | ៣៩ | ៤១០ | | | | |
| ២៣ | សាធារណការនិងដឹកជញ្ជូន | ១៤៩ | ១៥៥០ | | | | |
| ២៤ | យុត្តិធម៌ | ១៨ | ៦១ | | | | |
| ២៤.១ | អគ្គនាយកដ្ឋានកិច្ចការតុលាការ | ០០ | ៥៥៣ | | | | |
| ២៥ | ទេសចរណ៍ | ៣៩ | ៥២៩ | | | | |
| ២៦ | រៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ៦២ | ៣២៣ | | | | |

[1] ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ចទទួលបានក្របខណ្ឌចំនួន ១០កន្លែង និងមន្ត្រីជាប់កិច្ចសន្យាចំនួន ២៥០នាក់ សម្រាប់ផែនការឆ្នាំ២០១៧ និងទទួលបានក្របខណ្ឌពិសេសចំនួន២៩កន្លែង ដោយត្រូវកាត់ក្របខណ្ឌចំនួន ១០កន្លែង និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១៩នាក់ ចេញពីផែនការឆ្នាំ២០១៧

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៧ | | | | | |
|---|---|---|---|---|---|---|---|
| | | ក្របខណ្ឌ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនកម្រិត ជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅ | គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | គ្រូបង្រៀនកីឡានិង[illegible] |
| ២៧ | ធនធានទឹកនិងឧតុនិយម | ៣៩ | ៤៥៩ | | | | |
| ២៨ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤៦ | ៣៨៣ | | | | |
| ២៨.១ | គ្រូបណ្តុះបណ្តាលបច្ចេកទេស | ៣០០ | | | | | |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ០១ | ១៩០ | | | | |
| ៣០ | មុខងារសាធារណៈ | ០២ | ២៦០ | | | | |
| ៣១ | ឧស្សាហកម្មនិងសិប្បកម្ម | ២៥ | ២០០ | | | | |
| ៣២ | គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | ០៣ | ៧៥ | | | | |
| **សរុបរួម** | | ៦,៣៩២ | ១៦,៨៨២ | ១,៤៦២ | ៥,៩៨៧ | ២,៤៧២ | ១៦,៥១៨ |

យោងតាមចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដូចមានយោងខាងលើ ក្រសួងមុខងារសាធារណៈ សូមគោរពស្នើគ្រប់ក្រសួង ស្ថាប័ន មេត្តាសហការអនុវត្តនូវគោលការណ៍មួយចំនួនដូចខាងក្រោម៖

**១. វិធានការចំពោះការជ្រើសរើសនិងការប្រើប្រាស់ធនធានមនុស្សសម្រាប់ឆ្នាំ២០១៧**

**១.១ ការជ្រើសរើសដោយការប្រឡងប្រជែងផ្ទៃក្នុងពីចំណោមមន្ត្រីរាជការក្នុងក្រសួង ស្ថាប័នសាមី**

គ្រប់ក្រសួង ស្ថាប័ន ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ត្រូវរៀបចំឱ្យមានការប្រឡងប្រជែងផ្ទៃក្នុងក្រសួង ស្ថាប័នសាមីនីមួយៗជាមុន ដោយជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់ក្នុងក្រសួង ស្ថាប័នសាមី ដើម្បីបំពេញមុខតំណែងដែលត្រូវជ្រើសរើសទើបអាចធ្វើការប្រឡងប្រជែងជ្រើសរើសពីក្នុងចំណោមសិស្ស និស្សិតនិងមន្ត្រីរាជការទូទៅបាន។ ការអនុវត្តបែបនេះនឹងផ្តល់ឱកាសដល់មន្ត្រីរាជការអាចផ្លាស់ប្តូរអាជីពការងារក្នុងក្រសួង ស្ថាប័នតែមួយ ការពង្រាយមន្ត្រីពីកន្លែងលើសមន្ត្រីទៅកន្លែងខ្វះមន្ត្រី ព្រមទាំងអាចកាត់បន្ថយចំណាយមួយចំនួនថែមទៀត។

**១.២ ការជ្រើសរើសដោយការប្រឡងប្រជែងពីក្នុងចំណោមសិស្ស និស្សិតនិងមន្ត្រីរាជការទូទៅ**

បន្ទាប់ពីការប្រឡងប្រជែងផ្ទៃក្នុងពីចំណោមមន្ត្រីរាជការ ក្រសួង ស្ថាប័ន ត្រូវពិនិត្យឡើងវិញមុខតំណែងទំនេរដែលត្រូវជ្រើសរើស និងត្រូវធ្វើការប្រកាសជ្រើសរើសចេញពីការប្រឡងប្រជែងក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការទូទៅ និងប្រកាសលទ្ធផលជាប់ស្ពាតយ៉ាងយូរត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៧ ព្រមទាំងចាត់ចែងរៀបចំបើកផ្តល់បៀវត្ស ដល់បេក្ខជនប្រឡងជាប់ឱ្យបានរួចរាល់យ៉ាងយូរ ០១ខែ ក្រោយការប្រកាសលទ្ធផល។ ក្នុងករណីខកខានមិនបានរៀបចំការប្រឡងប្រជែងតាមកាលកំណត់ ត្រូវចាត់ទុកថាក្រសួង ស្ថាប័ន មិនមានតម្រូវការជ្រើសរើស

និងមិនត្រូវអនុញ្ញាតឱ្យធ្វើ ការជ្រើសរើសមន្ត្រីក្របខណ្ឌពីក្នុងចំណោមសិស្ស និស្សិត និងមន្ត្រីរាជការខុទ្ទកាល័យទៅក្នុងឆ្នាំ២០១៧ ឬនិយ័តទៅឆ្នាំបន្ទាប់ឡើយ។

**១.៣ ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីប្រភេទផ្សេងទៀត**

ក្រសួងមុខងារសាធារណៈ ឯកភាពផ្តល់ទិដ្ឋាការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា សម្រាប់ផែនការឆ្នាំ២០១៧ គ្រប់ក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត ដោយផ្តល់ប្រាក់កម្រៃប្រចាំខែគិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធ អនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងអនុវត្តអនុលោមតាមនីតិវិធីជាធរមាន។

ដោយឡែក គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះដឹងទូទៅ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងគ្រូបង្រៀនពីរវេន និងថ្នាក់គួបគ្រប់កម្រិត សម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ត្រូវអនុវត្តអនុលោមតាមនីតិវិធីជាធរមាន។

**២. សំណើសុំក្របខណ្ឌបន្ថែមលើគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល**

ជាគោលការណ៍ ក្រសួង ស្ថាប័ន ត្រូវពង្រឹងការប្រើប្រាស់ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របជាមួយនឹងគោលនយោបាយបង្កើនបៀវត្សរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក្នុងករណីដែលក្រសួង ស្ថាប័ន មានតម្រូវការចាំបាច់ប្រើប្រាស់ធនធានមនុស្សលើសពីគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល សំណើនេះត្រូវឆ្លងកាត់នីតិវិធីដូចខាងក្រោម៖

- ក្រសួង ស្ថាប័ន ត្រូវធ្វើការវិភាគមុខងារ រចនាសម្ព័ន្ធ ការពិពណ៌នាមុខតំណែងក្នុងក្រសួង ស្ថាប័ន សាមីជាមុន ដើម្បីធានានូវប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្ស
- ត្រូវមានការពិគ្រោះយោបល់ផ្នែកបច្ចេកទេស និងផ្នែកលទ្ធភាពថវិកាជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំការពិនិត្យនិងសម្រេចពីរាជរដ្ឋាភិបាល
- ការជ្រើសរើសត្រូវប្រកាសផ្សព្វផ្សាយនិងប្រឡងប្រជែងជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៅក្រសួង ស្ថាប័នដែលលើសមន្ត្រីរាជការជាមុន
- ក្រសួង ស្ថាប័នដែលអនុញ្ញាតឱ្យមន្ត្រីរាជការចូលរួមប្រឡងនិង/ឬចេញទៅបម្រើការងារនៅក្រសួង ស្ថាប័នដែលមានតម្រូវការជ្រើសរើស មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីថ្មី ទៅបំពេញជំនួសមុខតំណែងនោះឡើយ
- ក្នុងករណី ការប្រឡងជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការមិនសម្រេចបាន រាជរដ្ឋាភិបាលអនុញ្ញាតឱ្យមានការបើកការប្រឡងប្រជែងពីក្នុងចំណោមសិស្ស និស្សិត ក្នុងរយៈពេលយ៉ាងយូរ ៣ខែក្រោយ។ ប្រសិនបើពុំមានការរៀបចំការប្រឡងប្រជែតាមកាលកំណត់ត្រូវបានចាត់ទុកថាក្រសួង ស្ថាប័ន មិនមានតម្រូវការជ្រើសរើសឡើយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា នៅពេលបើកឱ្យមានការប្រឡងប្រជែង សូមមេត្តារៀបចំជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យចូលបម្រើការងារ ដើម្បីបំពេញមុខតំណែងដែលទំនេរ

និងសេចក្ដីត្រូវការដែលមានពិតប្រាកដនៅតាមអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងមន្ទីរអង្គភាពជំនាញ រាជធានី ខេត្ត ព្រមទាំងត្រូវយកចិត្តទុកដាក់ដល់បេក្ខភាពជាជនពិការដែលមានសមត្ថភាពសមស្រប ២% នៃចំនួនក្របខណ្ឌសរុបរបស់សាមីក្រសួង ស្ថាប័ន ហើយត្រូវមានបេក្ខនារីជាប់ជាស្ថាពរពី ២០% ទៅ ៥០% នៃចំនួនក្របខណ្ឌដែលទទួលបានប្រចាំឆ្នាំ។

សូម សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តារៀបចំស្នើសុំមន្ត្រីតំណាងក្រសួងមុខងារសាធារណៈ ចូលរួមក្នុងដំណើរការប្រឡងឱ្យបានមុនពេលរៀបចំបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសប្រចាំឆ្នាំ ដើម្បីក្រសួងមុខងារសាធារណៈមានលទ្ធភាពចូលរួមសហការចាប់តាំងពីដំណាក់កាលដំបូង។

សូម សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-នាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ
-មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត
"ដើម្បីសហការអនុវត្ត"
-ឯកសារ កាលប្បវត្តិ